01345414

E449

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 03 / 11 / 2016
ម៉ោង (Time/Heure): 13:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**ជូនចំពោះ÷** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ÷** សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល, សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសំណុំរឿង ០០២/០១ និង កិច្ចប្រជុំរៀបចំសវនាការ

១. អង្គជំនុំជម្រះសាលាដំបូងទទួលបានសំណើមួយ អនុលោមតាមវិធាន ៣៩ នៃវិធានផ្ទៃក្នុង និង មាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ របស់មេធាវីការពារក្តី នួន ជា ដែលបានដាក់នៅថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ (ឯកសារ E421/5 "សំណើសុំ") ដើម្បី (១) បន្ថែមពេលវេលា និង ចំនួនទំព័រសម្រាប់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលនៅក្នុងសំណុំរឿង ០០២/០២, (២) អនុញ្ញាតឲ្យដាក់សេចក្តីសន្និដ្ឋានស្ថាពរស្តីពីច្បាប់ជាធរមាន នៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោល ឬដាក់ដាច់ដោយឡែក មុនការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលនេះ និង (៣) រៀបចំកិច្ចប្រជុំរៀបចំសវនាការជាសាធារណៈឲ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន និង នៅមុនថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ដែលជាថ្ងៃដែលអង្គជំនុំជម្រះតុលាការកំពូលនឹងចេញសាលដីកានៅក្នុងសំណុំរឿង ០០២/០១។ មេធាវីការពារ

ក្តី ខៀវ សំផន បានដាក់ចម្លើយតប (ឯកសារ E421/5/1) នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៦។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ចម្លើយតប (ឯកសារ E421/5/2) នៅថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ហើយសហព្រះរាជអាជ្ញាបានដាក់ចម្លើយតប (ឯកសារ E421/5/3) នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៦។ នៅពេលនេះ អង្គជំនុំជម្រះសាលាដំបូងឆ្លើយតបទៅនឹងបញ្ហាបន្ទាន់ទាំងឡាយ ដែលបានលើកឡើងនៅក្នុងសំណើរបស់មេធាវីការពារក្តី នួន ជា ព្រមទាំងការកំណត់ពេលវេលាពាក់ព័ន្ធនានា។

២. ដោយសារតែការចេញសាលដីកានៅក្នុងសំណុំរឿង ០០២/០១ ត្រូវបានកំណត់ធ្វើឡើងនៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងនឹងមិនធ្វើសវនាការទេ ចាប់ពីថ្ងៃទី ២៣ ដល់ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ដើម្បីទុកលទ្ធភាពឲ្យភាគី និង អង្គជំនុំជម្រះ ពិនិត្យមើលសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល។

៣. អង្គជំនុំជម្រះយល់ស្របតាមសំណើសុំឲ្យរៀបចំកិច្ចប្រជុំរៀបចំសវនាការទៅលើបញ្ហាខាងក្រោមនេះ៖

(១) ចំនួនទំព័រនៃសារណាបញ្ចប់កិច្ចពិភាក្សាដេញដោល។

(២) ពេលវេលាកំណត់សម្រាប់ការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល។

(៣) ការកំណត់កាលបរិច្ឆេទធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលបន្ទាប់ពីការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល។

(៤) ទម្រង់ និង ការកំណត់ពេលវេលាដើម្បីដាក់សេចក្តីសន្និដ្ឋានស្តាពរស្តីពីច្បាប់ជាធរមាន។

(៥) ផលប៉ះពាល់នៃសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ដែលអាចមានមកលើការបិទបញ្ចប់សវនាការពិនិត្យដេញដោលភស្តុតាងក្នុងសំណុំរឿង ០០២/០២។

ប្រធានបទស្តីពីការទាមទារសំណងចុងក្រោយ និង អង្គហេតុចោទប្រកាន់ដែលនៅសេសសល់នៅក្នុងសំណុំរឿង ០០២ នឹងមិនត្រូវលើកយកមកដោះស្រាយនៅក្នុងកិច្ចប្រជុំរៀបចំសវនាការនេះទេ។

៤. ដោយហេតុថា កិច្ចប្រជុំពិភាក្សាពេញលេញមួយអាចធ្វើទៅបាន តែនៅក្រោយការប្រកាសសាលដីកានៅក្នុងសំណុំរឿង ០០២/០១ ប៉ុណ្ណោះនោះ អង្គជំនុំជម្រះយល់ឃើញថា កិច្ចប្រជុំ

E449

រៀបចំសវនាការគួរតែធ្វើឡើង នៅក្រោយថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦។ អង្គជំនុំជម្រះយល់ឃើញថា ជាការល្អដែលត្រូវទទួលសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរពីភាគីស្ដីពីផលប៉ះពាល់នៃសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ប្រសិនបើមាន មកលើការបិទបញ្ចប់សវនាការពិនិត្យដេញដោលភស្តុតាងនៃសំណុំរឿង ០០២/០២ ("សេចក្ដីសន្និដ្ឋានលើសាលដីកា") ដែលជាមូលដ្ឋានសម្រាប់សេចក្ដីសន្និដ្ឋាននៅពេលកិច្ចប្រជុំរៀបចំសវនាការ។ នៅពេលបច្ចុប្បន្ននេះ អង្គជំនុំជម្រះមានបំណងថា សារណាស្ដីពីផលប៉ះពាល់នៃសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលមកលើអង្គហេតុ និង អង្គច្បាប់ ក្រៅពីបញ្ហាអ្វីដែលអាចប៉ះពាល់ភ្លាមៗលើការពិភាក្សាដេញដោលពិនិត្យភស្តុតាងក្នុងសំណុំរឿង ០០២/០២ គួរតែលើកឡើងនៅពេលក្រោយ ជាពិសេសនៅក្នុងសារណា និងនៅក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល។

៥. អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងណែនាំដល់ភាគីឱ្យដាក់សេចក្ដីសន្និដ្ឋានលើសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល យ៉ាងយូរបំផុតត្រឹមថ្ងៃ ច័ន្ទ ទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៦។ កិច្ចប្រជុំរៀបចំសវនាការនឹងត្រូវធ្វើឡើងនៅថ្ងៃ ព្រហស្បតិ៍ ទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៦ ចាប់ផ្ដើមពីម៉ោង ៩:០០ ព្រឹក។

៦. អង្គជំនុំជម្រះកត់សម្គាល់ថា សវនាការពិភាក្សាដេញដោលពិនិត្យភស្តុតាងនឹងដំណើរការបន្តទៅតាមកាលវិភាគសវនាការជាធម្មតា (គឺ៤ ថ្ងៃ ក្នុងមួយសប្ដាហ៍) ចាប់ពីថ្ងៃទី ២៨ ខែ វិច្ឆិកា រហូតដល់ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៦។ នៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៦ ដែលជាថ្ងៃប្រជុំរៀបចំសវនាការនឹងមិនមានសវនាការទេ។ សវនាការពិភាក្សាដេញដោលពិនិត្យភស្តុតាងនឹងធ្វើនៅថ្ងៃ សុក្រ ទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៦។